ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

ក្រសួងរៀបចំដែនដី នគរូបនីយកម្ម និង សំណង់

អគ្គនាយកដ្ឋានសុរិយោដី និង ភូមិសាស្ត្រ

លេខ ២៧០ អ/ស.ភ

ភ្នំពេញ ថ្ងៃទី២៦ ខែ តុលា ឆ្នាំ ២០០៧

អគ្គនាយកដ្ឋានសុរិយោដី និង ភូមិសាស្ត្រ

ជំរាបមក

លោកប្រធានមន្ទីររៀបចំដែនដី នគរូបនីយកម្ម សំណង់ និងសុរិយោដី ក្រុងភ្នំពេញ

កម្មវត្ថុ : ករណីសំណើសុំកែតំរូវក្បាលដី លើវិញ្ញាបនប័ត្រសំគាល់ម្ចាស់អចលនវត្ថុ

យោង : លិខិតលេខ១១៥២ ចុះថ្ងៃ២១-០៨-០៧ របស់មន្ទីរដនសស.ក្រុង

តបតាមកម្មវត្ថុ និង យោងខាងលើ ខ្ញុំសូមជំរាបលោកប្រធានមន្ទីរថា ករណីក្បាលដីលេខ៩១៧ ដែលមានទីតាំងស្ថិតនៅភូមិគោកចំបក់ សង្កាត់ចោមចៅនេះ តម្រូវឱ្យកែឯកសារសុរិយោដីទាំងអស់ (ទិន្នន័យក្នុងឯកសារជាក្រដាស និងទិន្នន័យក្នុងDigital) មិនមែនកែតំរូវតែក្នុងវិញ្ញាបនប័ត្រសំគាល់ម្ចាស់អចលនវត្ថុនោះឡើយ ។ ដើម្បីបំពេញកិច្ចការនេះបាន អគ្គនាយកដ្ឋានសុរិយោដី និង ភូមិសាស្ត្រ សូមណែនាំដូចតទៅ :

១-ត្រូវធ្វើអត្តសញ្ញាណកម្មក្បាលដីឡើងវិញឱ្យបានត្រឹមត្រូវ ។

២-យកទិន្នន័យថ្មីដែលធ្វើអត្តសញ្ញាណកម្មក្រោយនេះ មកកែក្នុងឯកសារដូចតទៅ :

**ក-ទិន្នន័យក្នុងឯកសារជាក្រដាស :**

-ក្នុងប្លង់សុរិយោដី ត្រូវកែលេខក្បាលដី គឺដាក់លេខថ្មីដែលយកបន្តពីលេខចុងក្រោយនៃក្បាលដីក្នុងភូមិ ហើយលេខចាស់ត្រូវឆូតចោលដោយទឹកពណ៌ក្រហម ។

-ក្នុងទំរង់បែបបទនៃការប្រមូលទិន្នន័យក្បាលដី ត្រូវកែលេខ និងទំហំក្បាលដីឱ្យត្រូវតាមលេខ និងទំហំថ្មី ជាមួយគ្នានេះក៏ត្រូវកែលេខក្បាលដីជាប់ព្រំប្រសិនបើមានការប្រែប្រួលខុសពីទិន្នន័យមុន ។ ក្នុងបញ្ជីឈ្មោះម្ចាស់ដី ក៏ត្រូវកែតម្រូវឱ្យដូចគ្នាផងដែរ ។

-ក្នុងសៀវភៅគោលបញ្ជីដីធ្លី ត្រូវសរសេរក្នុងទំព័របំរុងទុក ឯទំព័រដែលខុសត្រូវបោះត្រាមោឃភាពចោល ។

-ចំពោះវិញ្ញាបនប័ត្រសំគាល់ម្ចាស់អចលនវត្ថុ ត្រូវបោះពុម្ពថ្មីចេញពីកុំព្យូទ័រក្រោយពេលកែតម្រូវទិន្នន័យរួច ឯវិញ្ញាបនប័ត្រសំគាល់ម្ចាស់អចលនវត្ថុចាស់ដែលខុសត្រូវប្រមូលយកមកបោះត្រាមោឃភាពចោល ។

អាស័យដ្ឋាន : លេខ ៧៧១-៧៧៣ មហាវិថី ព្រះមុនិវង្ស សង្កាត់ បឹងត្របែក ខណ្ឌ ចំការមន ក្រុងភ្នំពេញ

Tel (855) 023 215 659-215 660 Fax (855) 023 215 277 e-mail im_c_lm@Camnet.Com.Kh

ចំណាំ : គ្រប់ចំណុច និង ខ្លឹមសារកែប្រែលើឯកសារផ្លូវការ ត្រូវដាក់លេខយោង ដើម្បីសរសេរបញ្ជាក់អំពីឯកសារបន្ទាល់ដែលនាំឱ្យកែ រួចចុះហត្ថលេខា និងបោះត្រា សមត្ថកិច្ចដែលបានកែតម្រូវ ( ប្រធានមន្ទីរដនសស. ខេត្ត ) នៅចំណុចណាមួយនៃឯកសារដែលមិនចង្អៀត ។ អក្សរ និងលេខ ដែលសរសេរអំពីចំណុច និង ខ្លឹមសារកែតម្រូវ ត្រូវប្រើទឹមពណ៌ក្រហម ហើយហត្ថលេខា និង ត្រារបស់សមត្ថកិច្ចត្រូវប្រើទឹកពណ៌ខៀវ ឬខ្មៅ ។ ការលប់ទិន្នន័យចាស់ ត្រូវគូសបន្ទាត់ផ្ដេកកាត់ត្រង់ចំពាក់កណ្ដាលអក្សរ ឬលេខ ទុកឱ្យមើលឃើញ ។

**ខ-ទិន្នន័យក្នុង ឌីជីថល :**

ត្រូវកែតម្រូវឱ្យដូចគ្នាទាំងអស់ ក្នុងទិន្នន័យមូលដ្ឋាន/សៀវភៅគោលបញ្ជី ក្នុងParcel Index Map ។

ចំពោះទិន្នន័យកែថ្មី ពិសេសព្រំនៃក្បាលដីដែលមិនបានបិទផ្សាយជាសាធារណៈរយៈពេល៣០ថ្ងៃ តម្រូវឱ្យយកទិន្នន័យនេះមកបិទផ្សាយជាសាធារណៈឡើងវិញដើម្បីឱ្យមានអានុភាពគតិយុត្តគ្រប់គ្រាន់ ។

អាស្រ័យហេតុនេះ សូមលោកប្រធានមន្ទីរចាត់ចែងអនុវត្តតាមសេចក្ដីណែនាំនេះឱ្យមានប្រសិទ្ធភាពខ្ពស់ ។

អគ្គនាយក

ប៊ើម វ៉ាន់